**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២២១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ ៣៩ ៣៤៥ម៉ែត្រការ៉េ ស្ថិតនៅភូមិខ្លូងក្រាំង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងសម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុន ប៉េស្កូ អ៊ិនដាស្ទ្រី (ខេមបូឌា) គីធីអ៊ី អិលធីឌី ធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនអ្នកស្រី រត្ន សុភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៣៩ ៣៤៥ម² (សាមសិបប្រាំបួនពាន់បីរយសែសិបប្រាំម៉ែត្រការ៉េ) ដែលមានទីតាំងស្ថិតនៅភូមិខ្ទងក្រាំង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដូចមានប្លង់គំនូសបង្ហាញទីតាំង និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ប៉េស្តូ អ៊ិនដាស្ត្រី (ខេមបូឌា) ភីធីអ៊ី អិលធីឌី ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើផ្ទៃដីទំហំ ៣៩ ៣៤៥ម² (សាមសិបប្រាំបួនពាន់បីរយសែសិបប្រាំម៉ែត្រការ៉េ) ដែលមានទីតាំងស្ថិតនៅភូមិខ្ទងក្រាំង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជូនអ្នកស្រី រត្ន សុភាព។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១

**សាយអររដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែខនទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ប្លង់គំនូសបន្លាញទីតាំងដី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..២២១...អនក្រ.បក. ចុះថ្ងៃទី..១១....... ខែ..[illegible]......... ឆ្នាំ២០២១ ស្តីពី កាត់ឆ្វៀលដីទំហំ ៣៩ ៣៤៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិខ្លូងក្រាំង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ប៉េស្ត អ៊ិនជាស្ត្រី (ខេមបូឌា) អ៊ីធីអ៊ី អិលធីឌី និងផែនទីគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនអ្នកស្រី រត្ន សុនាត




| ID | X | Y |
|---|---|---|
| 1 | 418782.794 | 1265560.410 |
| 2 | 418659.969 | 1265560.709 |
| 3 | 418603.060 | 1265564.685 |
| 4 | 418603.000 | 1265565.000 |
| 5 | 418601.000 | 1265580.000 |
| 6 | 418584.000 | 1265787.000 |
| 7 | 418619.000 | 1265793.000 |
| 8 | 418635.000 | 1265795.000 |
| 9 | 418666.000 | 1265797.000 |
| 10 | 418693.000 | 1265793.000 |
| 11 | 418736.353 | 1265780.613 |
| 12 | 418749.952 | 1265770.900 |